*សូមផ្ទៀងផ្ទាត់តាមការអាន*

# សុន្ទរកថា
# អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
# ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឪជីវថល
# ថ្លែងក្នុង
# ពិធីបើកសិក្ខាសាលាផ្សព្វផ្សាយ
# ស្ដីពី
# «គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨»

ថ្ងៃ ពុធ ៥ រោច ខែ ភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
ថ្ងៃទី ៤ ខែ តុលា ឆ្នាំ ២០២៣ នៅសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ

- ឯកឧត្តម **ហែម វណ្ណឌី** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍;
- ឯកឧត្តម **ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍;
- ឯកឧត្តម **ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ;
- លោកជំទាវបណ្ឌិត **ជា សិរី** អគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា;
- ឯកឧត្តម, លោកជំទាវ, ឯកអគ្គរាជទូត, ឯកអគ្គរដ្ឋទូត ប្រចាំព្រះរាជាណាចក្រកម្ពុជា;
- ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី;
- ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ, ជាទីមេត្រី!

ថ្ងៃនេះ, ខ្ញុំពិតជាមានសេចក្តីសោមនស្សយ៉ាងក្រៃលែង ដោយបានមកចូលរួម ជាអធិបតី ក្នុងសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី «**គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨**» ។ ក្នុងឱកាសដ៏ប្រពៃនេះ, ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះ **ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី,** ជាថ្នាក់ដឹកនាំ, មន្ត្រីរាជការ, ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិទាំងអស់ ដែលបានឆ្លៀតពេលដ៏មានតម្លៃអញ្ជើញចូលរួមនៅក្នុងកម្មវិធីដ៏មានសារៈសំខាន់ នាព្រឹកនេះ, ទាំងនៅទីនេះផ្ទាល់ និង ទាំងនៅពីចម្ងាយ តាមប្រព័ន្ធអនឡាញ ។

ខ្ញុំនៅចាំបានថា កាលពីខែ មេសា ឆ្នាំ ២០២២, ខ្ញុំបានធ្វើជាអធិបតី ក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពី «**គោលនយោបាយ និង ទិសដៅនៃបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា**», ដែលកាលនោះ, **ក្រុមការងាររៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា** ទើបចាប់ផ្តើមធ្វើការពិគ្រោះយោបល់ និង ប្រមូលធាតុចូលល្អៗពីគ្រប់តួអង្គពាក់ព័ន្ធ សម្រាប់ជាមូលដ្ឋានក្នុងការតាក់តែងឯកសារគោលនយោបាយនេះ ។ «**គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨**», ដែលយើងបានចាយពេលអស់ប្រមាណមួយឆ្នាំ ដើម្បីរៀបចំបានចប់សព្វគ្រប់, ពេញលេញ និង គ្រប់ជ្រុងជ្រោយ, រហូតត្រូវបានដាក់ផ្សព្វផ្សាយជាសាធារណៈ នាថ្ងៃនេះ, គឺជាសមិទ្ធផលមួយដ៏មានសារៈសំខាន់ គួរជាទីមោទនៈ សម្រាប់ជាមគ្គទេសក៍ក្នុងការជំរុញការប្រើប្រាស់បច្ចេកវិទ្យាក្នុងវិស័យហិរញ្ញវត្ថុ ដែលត្រូវបានហៅកាត់ថា៖ «**បច្ចេកវិទ្យាហិរញ្ញវត្ថុ**» ឬ «FinTech» ជាភាសាអង់គ្លេស, សំដៅចូលរួមលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ, រក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ និង ជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ ។ ខ្ញុំជឿជាក់យ៉ាងមុតមាំថា ការអនុវត្តគោលនយោបាយនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ នឹងជួយឱ្យកម្ពុជាអាចទាញយកអត្ថប្រយោជន៍ជាអតិបរមាពីបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ និង ផ្តល់កាលានុវត្តភាពដល់គ្រប់តួអង្គ សំដៅរួមចំណែកជំរុញសម្ទុះនៃការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ឱ្យកាន់តែមានភាពរស់រវើក ។

## *ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!*

ក្នុងរយៈពេល ២៥ ឆ្នាំ ចុងក្រោយនេះ, ក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាពពេញផ្ទៃប្រទេស ដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បាននាំមកជូនប្រទេសជាតិ

និង ប្រជាជន តាមរយៈ **នយោបាយឈ្នះ-ឈ្នះ**, កម្ពុជាបន្តសម្រេចបាននូវសមិទ្ធផលធំៗជាច្រើន ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង បានផ្លាស់ប្តូរមុខមាត់គួរជាទីមោទនៈ តាមរយៈការអនុវត្ត ប្រកបដោយជោគជ័យ នូវ **យុទ្ធសាស្ត្រត្រីកោណ និង យុទ្ធសាស្ត្រចតុកោណ, ទាំងបួនដំណាក់កាល,** ព្រមទាំងគោលនយោបាយ និង ផែនការយុទ្ធសាស្ត្រពាក់ព័ន្ធផ្សេងទៀត ។ ខ្ញុំសូមគូសបញ្ជាក់ថា ការដាក់ចេញនូវគោលនយោបាយត្រឹមត្រូវ, មុតស្រួច និង ទាន់ពេល បានជំរុញឱ្យកម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងអត្រាប្រមាណ ៧% ជាមធ្យម ក្នុងមួយឆ្នាំ ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ មុនការ-មកដល់នៃជំងឺកូវីដ-១៩ ។ លើសពីនេះ, ជាមួយនឹងមូលដ្ឋានសង្គម-សេដ្ឋកិច្ចដ៏រឹងមាំ ប្រកបដោយចីរភាព, បរិយាប័ន្ន, សមធម៌ និង ធន់នឹងវិបត្តិ, សេដ្ឋកិច្ចជាតិបាន និង កំពុងបន្តងើបឡើងវិញ បន្ទាប់ពីទទួលរងនូវការបង្អាក់ ដោយវិបត្តិជាសកលនៃជំងឺកូវីដ-១៩ និង ទោះបីជាកម្ពុជា ត្រូវបន្តជួបប្រឈមនឹងសភាពការណ៍សកល ដែលមានភាពមិនប្រាកដ-ប្រជាខ្ពស់ក៏ដោយ រួមមាន៖ ភាពតានតឹងនៃស្ថានភាពភូមិសាស្ត្រនយោបាយ, ពិសេសសង្គ្រាមរវាងរុស្ស៊ី និង អ៊ុយក្រែន, និង កំណើនយឺតនៃសេដ្ឋកិច្ចសកល, ព្រមទាំងការថមថយនៃតម្រូវការនៅតាមបណ្តាប្រទេសជាដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា ជាដើម ។

សមិទ្ធផលទាំងនេះក៏បាន និង កំពុងជំរុញ និង លើកទឹកចិត្តដល់រាជរដ្ឋាភិបាល, ក្រោមការដឹកនាំប្រកបដោយជវភាពរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយក-រដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**, ឱ្យបន្តបង្កើនកិច្ចខិតខំប្រឹងប្រែង និង សម្លឹងឆ្ពោះទៅមុខប្រកបដោយក្តីសង្ឃឹម, ភាពជឿជាក់ និង ឆន្ទៈមោះមុត ក្នុងការសម្រេចបាននូវចក្ខុវិស័យនៃការប្រែក្លាយកម្ពុជា ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០ និង ជាប្រទេសដែលមានចំណូលខ្ពស់ នៅឆ្នាំ ២០៥០ ។

### *ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!*

ក្នុងយុគសម័យបដិវត្ត ឧស្សាហកម្មថ្មី ៤.០, បច្ចេកវិទ្យាឌីជីថលបានបោះជំហានយ៉ាងលឿន និង បានក្លាយជាកត្តាគន្លឹះ ជំរុញការគ្របដណ្តប់ និង ការតភ្ជាប់សង្គម និង សេដ្ឋកិច្ចនៅទូទាំងពិភពលោក ឱ្យកាន់តែស្អិតល្មួត, ខិតជិតគ្នា និង ពឹងគ្នាទៅវិញទៅមក ។ បច្ចុប្បន្ន, គ្រប់វិស័យនៃសេដ្ឋកិច្ច និង តំបន់ភូមិសាស្ត្រ, ទាំងទីប្រជុំជន និង ជនបទ; ព្រមទាំងបុគ្គល, ទាំងវ័យក្មេង និង វ័យចំណាស់, សុទ្ធសឹងកំពុងទទួលឥទ្ធិពលពីបច្ចេកវិទ្យា,

ជាពិសេស បច្ចេកវិទ្យាឌីជីថល ដែលបាន និង កំពុង៖ (១)-កែប្រែរបៀបក្នុងការធ្វើធុរកិច្ច ឬ ម៉ូដែលធុរកិច្ច; (២)-ផ្លាស់ប្តូរទម្លាប់រស់នៅ ឬ ជីវិតប្រចាំថ្ងៃ ក្នុងការប្រាស្រ័យទាក់ទង និង ការបំពេញការងារ; និង (៣)-ពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និង ប្រសិទ្ធភាពការងារ ។ មិនថាមានការអភិវឌ្ឍក្នុងកម្រិតណានោះទេ, ប្រទេសដែលមានសេដ្ឋកិច្ចកំពុងលូតលាស់ ឬ ប្រទេសកំពុងអភិវឌ្ឍ អាចចាប់យកនូវបច្ចេកវិទ្យាឌីជីថលថ្មីៗ ដើម្បីផ្លាស់ប្តូរពីឧស្សាហកម្មបែបប្រពៃណី ទៅឧស្សាហកម្មទំនើបបាន ក្នុងរយៈពេលខ្លី តាមរយៈ៖ (១)-ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលជាវិស័យចន្លល់ ក្នុងការជំរុញកំណើនសេដ្ឋកិច្ច; (២)-ការប្រែក្លាយបច្ចេកវិទ្យាឌីជីថលជាកាតាលីករ ក្នុងការគាំទ្រ និង ជំរុញវិស័យផ្សេងៗនៃសេដ្ឋកិច្ច; និង (៣)-ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីផ្តល់លទ្ធភាពឱ្យធុរជន និង វិនិយោគិនក្នុងស្រុក អាចភ្ជាប់ខ្លួនទៅនឹងខ្សែច្រវាក់ផលិតកម្មតំបន់ និង សកល ក៏ដូចជាស្វែងរកភាពច្នៃប្រឌិត ក្នុងការផលិតទំនិញ និង ការផ្តល់សេវាកម្ម ។

ក្នុងការកសាងមូលដ្ឋានឆ្ពោះទៅរកការសម្រេចបាន នូវចក្ខុវិស័យរយៈពេលវែងរបស់ខ្លួន និង ដោយមើលឃើញពីសក្តានុពលនៃវិស័យបច្ចេកវិទ្យាឌីជីថលនេះ, រាជរដ្ឋាភិបាលបានដាក់ចេញនូវ «**ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥**» និង «**គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥**» ដែលជាផែនទីបង្ហាញផ្លូវ និង ជាក្របខណ្ឌការងារនៃការគិតគូរវែងឆ្ងាយរបស់រាជរដ្ឋាភិបាល ក្នុងការទាញយកប្រយោជន៍ជាអតិបរមា ពីបច្ចេកវិទ្យាឌីជីថល ដើម្បីអភិវឌ្ឍសង្គម និង សេដ្ឋកិច្ច ។ ជាងនេះទៀត, រាជរដ្ឋាភិបាល, នីតិកាលទី ៧ នៃរដ្ឋសភា, ក៏បានដាក់ចេញនូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ដោយកំណត់យកអាទិភាពគន្លឹះចំនួន **៥** រួមមាន៖ **មនុស្ស, ផ្លូវ, ទឹក, ភ្លើង** និង **បច្ចេកវិទ្យា** ។ ក្នុងនោះ, **ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល** ត្រូវបានរំលេចយ៉ាងច្បាស់ ដោយត្រូវបានកំណត់ក្នុងបញ្ចកោណទី ៥ ហើយ **ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ** គឺជាមុំមួយ ក្នុងចំណោមមុំទាំង ៥ នៃបញ្ចកោណទី ៥ ។

នៅមុននេះបន្តិច, សុន្ទរកថាគន្លឹះរបស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** ដែលបានផ្តោតលើទិដ្ឋភាពវិស័យហិរញ្ញវត្ថុមិនមែនធនាគារ និង សុន្ទរកថាគន្លឹះរបស់ **លោកជំទាវបណ្ឌិត ជា សិរី អគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា** ដែលបានផ្តោតលើទិដ្ឋភាពហិរញ្ញវត្ថុ ក្នុងវិស័យធនាគារ, បានឆ្លុះបញ្ចាំងឱ្យឃើញពីសម្ទុះនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ, ទាំងវិស័យធនាគារ និង វិស័យហិរញ្ញវត្ថុមិនមែន

ធនាគារ ។ ក្នុងនោះ, បច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលបានរួមចំណែកក្នុងការជំរុញការអភិវឌ្ឍវិស័យទាំងពីរនេះ មានសន្ទុះរីកចម្រើនយ៉ាងរហ័ស, ទាំងទំហំ និង វិសាលភាព, ជាពិសេសតាមរយៈការចាប់យកបច្ចេកវិទ្យាថ្មីៗ ដើម្បីបង្កើត និង ធ្វើឱ្យកាន់តែប្រសើរ នូវសេវា និង ផលិតផលហិរញ្ញវត្ថុ ។

## *ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!*

ដើម្បីចាប់យកកាលានុវត្តភាព និង សក្តានុពលដ៏ធំធេង ពីបច្ចេកវិទ្យាហិរញ្ញវត្ថុ, រាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចជូនគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល ក្នុងការដឹកនាំ និង ការសម្របសម្រួល ដើម្បីរៀបចំ «**គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨**» ដែលបានកំណត់ចក្ខុវិស័យរយៈពេលវែង ប្រកបដោយមហិច្ឆតា និង ភាពប្រាកដនិយម គឺ «**អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ដោយឈរលើមូលដ្ឋាននៃការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ, ការរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ និង ការជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ ដើម្បីចាប់យកអត្ថប្រយោជន៍ជាអតិបរមា ពីបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ និង ផ្តល់កាលានុវត្តភាពដល់គ្រប់តួអង្គ សំដៅរួមចំណែកជំរុញសន្ទុះនៃការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជាដ៏រស់រវើក**» ដោយឈរលើគោលការណ៍ធំៗចំនួន ៣ រួមមាន៖ (១)-ការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ; (២)-ការរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ; និង (៣)-ការជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ ។

ក្នុងទិសដៅនេះ, «**គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨**» បានកំណត់គោលដៅចម្បងចំនួន ៤ ដោយចាត់ទុកការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុជាដើមឈើមួយដើម ឬ ហៅថា **ដើមឈើបច្ចេកវិទ្យាហិរញ្ញវត្ថុ** (FinTech Tree) ដោយរួមបញ្ចូលនូវ៖ (១)-ការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផល ដែលតំណាងដោយ «**ដី**»; (២)-ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះ ដែលតំណាងដោយ «**ឫស**»; (៣)-ការជំរុញការប្រើប្រាស់ និង ការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ ដែលតំណាងដោយ «**ដើម**»; និង (៤)-ការជំរុញការអភិវឌ្ឍ និង នវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលតំណាងដោយ «**មែក**» ។

ដើម្បីឱ្យការអនុវត្តគោលនយោបាយនេះ សម្រេចបានជោគជ័យ, វិធានការគោលនយោបាយ **សរុបចំនួន ៥២** ត្រូវបានដាក់ចេញ ដោយការអនុវត្តវិធានការគោលនយោបាយទាំងអស់នេះ ត្រូវគោរពតាមអភិក្រមចំនួន ៣ គឺ៖ **ទី១**)-ការចាប់យក (Adoption);

**ទី២)**-ការកែសម្រប (Adaptation); និង **ទី៣)**-ការធ្វើនវានុវត្តន៍បន្ថែម (Further Innovation) ដោយឈរលើគោលដំហរ «**ថៃទាំដើមឈើឱ្យលូតលាស់ល្អ និង អាស្រ័យផលបាន ត្រូវការដីមានជីជាតិដែលអំណោយផលដល់ការស្រូបយករបស់ឫស; ឫសរឹងមាំ និង ច្រើន ដែលអាចស្រូបយកជីជាតិបានល្អ សម្រាប់ទ្រទ្រង់ដល់ភាពរឹងមាំរបស់ដើម; ដើមរឹងមាំសម្រាប់ទ្រទ្រង់ដល់ការលូតលាស់ល្អរបស់មែក និង មែកបែកសាខា ប្រកបដោយផ្លែផ្កាច្រើន ដែលអាចអាស្រ័យផលបាន**» ។ ជាការពិតណាស់, ដោយសម្លឹងឃើញការវិវឌ្ឍយ៉ាងរហ័សនៃវិស័យបច្ចេកវិទ្យា ដែលពិបាកប៉ាន់ប្រមាណ, ឯកសារគោលនយោបាយនេះ ត្រូវបានចាត់ទុកជា «**ឯកសាររស់**» ដែលជាកម្មវត្ថុនៃការកែសម្រួលបន្ថែម នាអនាគត អនុលោមតាមឧត្តមានុវត្តន៍អន្តរជាតិ និង និន្នាការនៃការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុជាក់ស្តែង ។

ដើម្បីសម្រេចចក្ខុវិស័យ និង គោលបំណងនៃគោលនយោបាយនេះ និង ដើម្បីឱ្យវិធានការគោលនយោបាយដែលត្រូវបានដាក់ចេញ អាចសម្រេចបានប្រកបដោយប្រសិទ្ធ-ភាពខ្ពស់, ខ្ញុំសូមស្នើឱ្យក្រសួង-ស្ថាប័ន និង គ្រប់តួអង្គពាក់ព័ន្ធ យកចិត្តទុកដាក់លើការងារសំខាន់ៗចំនួន ៥ ដូចខាងក្រោម៖

**ទី១**-ក្រសួង-ស្ថាប័នទទួលបន្ទុកអនុវត្តវិធានការគោលនយោបាយ ត្រូវរៀបចំផែនការសកម្មភាពការងារជាក់ស្តែង ហើយគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល ត្រូវបន្តសហការជាមួយក្រសួង-ស្ថាប័ន និង ភាគីពាក់ព័ន្ធ ដើម្បីរៀបចំយន្តការក្របខណ្ឌតាមដាន និង វាយតម្លៃ ដោយកំណត់សូចនាករសមិទ្ធកម្មគន្លឹះ ឱ្យបានច្បាស់លាស់ ។

**ទី២**-ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវបន្តចូលរួមឱ្យបានពេញលេញ ក្នុងការអនុវត្តគោល-នយោបាយនេះ ប្រកបដោយស្មារតីបុរេសកម្ម, ភាពម្ចាស់ការ និង ការទទួលខុសត្រូវខ្ពស់ ។

**ទី៣**-ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវបន្តស្រាវជ្រាវដកស្រង់ពិសោធន៍ និង រៀនសូត្រជាប់ជាប្រចាំ ដោយត្រូវពង្រឹងសមត្ថភាពស្ថាប័នរបស់ខ្លួន ឱ្យបានកាន់តែប្រសើរ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការទាញយកប្រយោជន៍ជាអតិបរិមាពីបច្ចេកវិទ្យាដែលកំពុងលេចឡើងថ្មីៗទាំងនេះ ។

**ទី៤**-គ្រប់តួអង្គពាក់ព័ន្ធ, ទាំងរដ្ឋ និង ឯកជន, នៃប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុត្រូវបន្តកិច្ចសហការជិតស្និទ្ធ, ចូលរួមដោយសកម្ម និង ធ្វើការបំពេញឱ្យគ្នាទៅវិញទៅមក,

ដើម្បីបង្កើតសហថាមពល (Synergy) និង បរិស្ថានអំណោយផល ដល់ការអភិវឌ្ឍបច្ចេក-វិទ្យាហិរញ្ញវត្ថុដ៏រស់រវើក ។

**ទី៥**-គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល ត្រូវបន្តកិច្ចសហការជិតស្និទ្ធជាមួយធនាគារជាតិនៃកម្ពុជា, អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, សមាគម, វិស័យឯកជន និង គ្រប់តួអង្គពាក់ព័ន្ធទាំងអស់, ដើម្បីរួមគ្នារៀបចំជាវេទិកាថ្នាក់ជាតិ ឬ អន្តរជាតិស្តីពីបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាប្រចាំឆ្នាំ, ដោយមានការចូលរួមទាំងវិស័យធនាគារ និង មិនមែនធនាគារ, ដើម្បីបង្កើតទំនាក់ទំនង, ពិភាក្សា និង ចែករំលែកមេរៀន និង ពិសោធន៍ល្អៗ ក៏ដូចជាដើម្បីស្វែងយល់អំពីបញ្ហាប្រឈម ឬ ក្តីកង្វល់នានា ដើម្បីស្វែងរកដំណោះស្រាយតាមជាក់ស្តែង ។

## *ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!*

ដូចឯកឧត្តមបណ្ឌិត **គង់ ម៉ារី** បានគូសបញ្ជាក់ក្នុងរបាយការណ៍មុននេះបន្តិច, ក្នុងសិក្ខាសាលានេះ នឹងមានការធ្វើបទបង្ហាញ ស្តីពីខ្លឹមសារសង្ខេបនៃ «**គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨**» ព្រមទាំងមានកិច្ចពិភាក្សាស្តីពី **ទិដ្ឋភាពបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា និង ការអនុវត្តគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨** ដែលជារបៀបវារៈបន្តក្នុងពិធីផ្សព្វផ្សាយ នាព្រឹកនេះ ។ ហេតុនេះ, ខ្ញុំសូមលើកទឹកចិត្តឱ្យអង្គពិធីទាំងមូល យកចិត្តទុកដាក់ស្តាប់បទបង្ហាញ និង ចូលរួមវេទិកាពិភាក្សាឱ្យបានផុសផុល ដោយយកឱកាសនៃការជួបជុំគ្នា នាថ្ងៃនេះ ដើម្បីបង្កើតទំនាក់ទំនង, ចែករំលែកមេរៀន និង ពិសោធន៍ ដែលអាចនឹងរួមចំណែកបង្កើតសហគមន៍បច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាមួយដ៏សកម្ម និង រស់រវើក នាអនាគត ។

មុននឹងបញ្ចប់, ខ្ញុំសូមអរគុណចំពោះក្រសួង-ស្ថាប័ន, ដៃគូអភិវឌ្ឍន៍ និង វិស័យឯកជនទាំងអស់, ជាពិសេស ធនាគារជាតិនៃកម្ពុជា និង អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ដែលបានចូលរួមយ៉ាងសកម្ម និង បានផ្តល់កិច្ចសហការជិតស្និទ្ធជាមួយគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល នាពេលកន្លងមក រហូតឯកសារគោលនយោបាយដ៏មានសារៈសំខាន់នេះ ត្រូវបានបញ្ចប់ជាស្ថាពរ និង ត្រូវបានប្រកាសផ្សព្វផ្សាយ នាឱកាសនេះ ។

ជាទីបញ្ចប់, ខ្ញុំសូមជូនពរឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី, សមាជិក, សមាជិកានៃអង្គពិធីទាំងមូល បានប្រកបដោយសុខភាពបរិបូរណ៍, មានសុភមង្គលក្នុងក្រុមគ្រួសារ និង សម្រេចជោគជ័យក្នុងគ្រប់កិច្ចការ ។

ខ្ញុំមានកិត្តិយស សូមប្រកាសបើកសិក្ខាសាលាផ្សព្វផ្សាយស្តីពី **«គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨»** នាពេលនេះ ៕

***សូមអរគុណ!***